**ប្រការ៧ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ៨ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចូន់ចូរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៩ :** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ស៊ីណូ-ណេយ៉េរ ហ្គាមេន (ខេមបូឌា) ខូអិល ធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

**ប្រការ១០:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ហត្ថលេខា និងត្រា**

**ស៊ុយ សែម**

===

## ២-នីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០១

**ប្រកាសលេខ ១៩១ ប្រក.កសក**

**ស្តីពីវិធានការទប់ស្កាត់ការនាំចូលសត្វគោ សត្វធំពាររមៀង និងផលិតផលមានដើមកំណើតពីសត្វគោ សត្វធំពាររមៀង ពីបរទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា**

---

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញសេចក្តីសំរេចលេខ ,០៥ សសរ ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០១ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវ និងទប់ស្កាត់ការនាំចូលតាមច្រកព្រំដែននូវសត្វរស់ ផលិតផលមានដើមកំណើតពីសត្វ និងគ្រឿងបរិភោគ ដែលបណ្តាលអោយប៉ះពាល់ដល់សុខភាពសាធារណៈ

-បានឃើញលិខិតលេខ ២៧៨ សជណ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីជំងឺគោឆ្កួតនៅ ១៣ ប្រទេសនៃទ្វីបអឺរ៉ុប និងវិធានការទប់ស្កាត់

-បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**ប្រការ១** : ហាមឃាត់ការនាំចូលសត្វគោ សត្វទំពារអៀង និង ផលិតផលមានដើមកំណើតពីសត្វគោ និងសត្វទំពារអៀង ពីប្រទេសចំនួន ១៣ នៃសហគមន៍អឺរ៉ុប ( អង់គ្លេស បែលហ្ស៊ិក ដាណឺម៉ាក បារាំង អាល្លឺម៉ង់ អៀរឡង់ លុចសំបួរ ហូឡង់ ព័រទុយហ្គាល់ អេស្បាញ ស្វីស កាណាដា និង អ៊ីតាលី ) ។

**ប្រការ២** : ការនាំចូលសត្វគោ សត្វទំពារអៀង និងផលិតផលមានដើមកំណើតពីសត្វគោ និងសត្វទំពារអៀង ពីបណ្តាប្រទេសផ្សេងៗ ទៀត ដែលពុំមានបញ្ជាក់ថាមានជំងឺ BSE ភាសាសាមញ្ញហៅថាជំងឺគោឆ្កួត ចាំបាច់ត្រូវមានគោលការណ៍អនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថិតក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់នាយកដ្ឋាន ផលិតកម្ម និងបសុពេទ្យាបាល ។

**ប្រការ៣** : ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស អគ្គនាយកក្រសួង អគ្គាធិការ នាយខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល ប្រធានមន្ទីរកសិកម្ម រុក្ខា

ប្រមាញ់ និងនេសាទគ្រប់ខេត្ត-ក្រុង ត្រូវទទួលអនុវត្តសេចក្តីប្រកាសនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ម៉ៅ សំអឿន**